# គន្លងនៃកាតព្វកិច្ចរបស់យើង

*ប៊ីស្សព យេស៍ ប៊ី ម៉ាក់មូលីន*
*ទីប្រឹក្សាទីពីរ នៃគណៈប៊ីស្សពអធិបតី*

នេះគឺជាពិភពលោកមួយពោរពេញទៅដោយបញ្ហា។ ចម្បាំង និងគ្រោះមហន្តរាយមាននៅគ្រប់ទីកន្លែងទាំងអស់។ ជួនកាលវាហាក់ដូចជាមនុស្សខ្លួនឯងកំពុងចងភ្ជួរខ្លួនឯង។ គ្រោះមហន្តរាយធម្មជាតិបំផ្លិចបំផ្លាញខ្ទេចខ្ទី ក៏ដូចជាប្រភេទសោកនាដកម្មនៅក្នុងបុគ្គលម្នាក់ៗ ដូចជា ភាពមិនស្មោះត្រង់ ភាព-ឃោរឃៅ និងការខ្វះភក្ដីភាព។

ដោយទស្សន៍ទាយអំពីសម័យយើងបច្ចុប្បន្ន ព្រះអម្ចាស់បានមានព្រះបន្ទូលថា «ផ្ទៃមេឃនឹងញាប់ញ័រ ហើយព្រមទាំងផែនដីផងដែរ ហើយនឹងមានសេចក្ដីវេទនាដ៏ធំនៅក្នុងចំណោមកូនចៅមនុស្ស *ប៉ុន្តែរីឯរាស្ត្រយើងវិញ នោះនឹងរក្សាទុក*» យើងគួរតែទទួលបាននូវការលួងលោមដោយការសន្យានេះ។

ទោះជាមហន្តរាយបំផ្លាញ «សូម្បីតែអត្ថន័យនៃវិធីរបស់យើង» មហន្តរាយទាំងនេះមិនទុកឲ្យជីវិតយើងខ្ទេចខ្ទីជារៀងរហូតឡើយ។  ពួកវាអាច «ដាស់រំជួលគេ» «ធ្វើឲ្យ [យើង]ភ្ញាក់រំឭកដល់កិច្ចការរបស់អ្នកចំពោះព្រះ» និងរក្សាយើងឲ្យដើរតាមគន្លងនៃ...ករណីកិច្ចរបស់យើង»។

នៅក្នុងប្រទេសហូឡង់ ក្នុងអំឡុងសង្គ្រាមលោកលើកទី២ គ្រួសារ ខាស្ទើរ ធេន ប៊ូម ប្រើគេហដ្ឋានរបស់ពួកគេជាទីលាក់ខ្លួនសម្រាប់អ្នកដែលត្រូវតាមសម្លាប់ដោយពួកណាស៊ីស ។ នេះគឺជាវិធីរស់នៅរបស់ពួកគេទៅតាមសេចក្តីជំនឿជាគ្រីស្ទាន ។ សមាជិកបួននាក់ក្នុងគ្រួសារបានបាត់បង់ជីវិតដោយសារតែផ្ដល់ជំរកដល់ ជនភាសខ្លួន ។ ខូរី ធេន ប៊ូម និងប្អូនស្រីរបស់នាង បេិតស៊ី ចំណាយពេលរាប់ខែយ៉ាងលំបាកលំបិននៅក្នុងជំរំ រ៉ាវេនសាបាក់ ដែលមានឈ្មោះដ៏អាក្រក់មួយ។

នៅក្នុងរ៉ាវេនសាបាក់ ខូរី និងបេិតស៊ី បានរៀនថា ព្រះជួយយើងឲ្យចេះអភ័យទោស។ ក្រោយពីសង្គ្រាម ខូរីបានតាំងចិត្តដើម្បីចែកចាយសារដំណឹងនេះ។ នៅក្នុងពេលមួយ នាងបាននិយាយទៅកាន់មនុស្សមួយក្រុម នៅក្នុងប្រទេសអាល្លឺម៉ង់ ដែលទទួលរងគ្រោះដោយសារមហន្តរាយនៃសង្គ្រាម។ សារដំណឹងរបស់នាងគឺ «ព្រះទ្រង់អភ័យទោស»។ គឺនៅពេលនោះហើយដែលភាពស្មោះត្រង់របស់ ខូរី ធេន ប៊ូម បាននាំមកនូវពរជ័យ។

បុរសម្នាក់បានដើរទៅជិតនាង។ នាងបានស្គាល់គាត់ជាឆ្មាំគុកដ៏កាចសាហាវម្នាក់នៅក្នុងជំរំ។ គាត់បាននិយាយថា «អ្នកបានរំឭកអំពីរ៉ាវេនសាបាក់នៅក្នុងការនិយាយរបស់អ្នក។ ខ្ញុំបានធ្វើជាឆ្មាំយាមនៅទីនោះ។ ប៉ុន្តែចាប់តាំងពីពេលនោះមក ខ្ញុំបានក្លាយខ្លួនជាគ្រីស្ទានម្នាក់»។ គាត់ពន្យល់ថា គាត់បានស្វែងរកការអភ័យទោសរបស់ព្រះចំពោះរឿងដ៏ឃោរឃៅដែលគាត់បានធ្វើ។ គាត់បានលាតដៃរបស់គាត់ចេញមក ហើយសួរថា «តើអ្នកនឹងអភ័យទោសឲ្យខ្ញុំទេ?»

ខូរី ធេន ប៊ូម បាននិយាយនៅពេលនោះថា៖ «វាមិនយូរជាងប៉ុន្មានវិនាទីដែលគាត់បានឈរនៅទីនោះ---លាតដៃចេញមក---ប៉ុន្តែចំពោះខ្ញុំ វាហាក់ដូចជារាប់ម៉ោង នៅពេលខ្ញុំតាំងនឹងរឿងដែលលំបាកបំផុតដែលខ្ញុំមិនដែលធ្លាប់ធ្វើពីមុនមក...។ សារដំណឹងដែលថា ព្រះទ្រង់អភ័យទោសមាន...លក្ខខ័ណ្ឌមួយថា៖ យើងអភ័យទោសដល់ អ្នកដែលធ្វើឲ្យយើងឈឺចាប់....ខ្ញុំបានអធិស្ឋានដោយស្ងាត់ថា «ជួយខ្ញុំផង! ខ្ញុំអាចលើកដៃរបស់ខ្ញុំ។ ខ្ញុំអាចធ្វើអ្វីៗក៏បាន។ សូមទ្រង់ប្រទាននូវអារម្មណ៍មកដល់ខ្ញុំផង»។

«ដោយលំបាក ខ្ញុំបានបង្ខំដៃរបស់ខ្ញុំទៅចាប់ដៃដែលលូកមកចាប់ដៃខ្ញុំ។ នៅពេលខ្ញុំធ្វើដូច្នេះ រឿងដែលមិនគួរឲ្យជឿបានកើតឡើង។ រលកបានចាប់ផ្ដើមពីស្មាហូរដល់ដៃរបស់ខ្ញុំ បោកបក់ទៅលើដៃទាំងពីរដែលចាប់គ្នា។ ហើយនៅពេលនោះ កំដៅនៃការព្យាបាលនេះហាក់ដូចជាជោរជន់ខ្លួនខ្ញុំទាំងមូល បង្កើតឲ្យមានទឹកភ្នែកនៅក្នុងភ្នែករបស់ខ្ញុំ។

«ខ្ញុំបានយំដោយនិយាយថា ខ្ញុំអភ័យទោសដល់អ្នក បងប្រុសដោយអស់ពីដួងចិត្តរបស់ខ្ញុំ» យើងបានចាប់ដៃគ្នាទៅវិញទៅមកអស់រយៈពេលមួយយ៉ាងយូរ អតីតឆ្មាំយាម និង អតីតអ្នកទោស។ ខ្ញុំមិនធ្លាប់ដែលដឹងថា សេចក្ដីស្រលាញ់របស់ព្រះពិតជាខ្លាំងក្លាដូចដែលខ្ញុំដឹងនៅពេលនោះឡើយ»។

ចំពោះអ្នកណាដែលជៀសវាងអំពើអាក្រក់ ហើយរស់នៅដោយសុចរិត អ្នកណាដែលតស៊ូដើម្បីថ្ងៃដែលភ្លឺជាងមុន ហើយគោរពតាមបញ្ញត្តិព្រះ រឿងរ៉ាវនានានឹងអាចបានប្រសើរឡើង សូម្បីតែនៅពេលប្រឈមមុខនឹងសោកនាដកម្ម ក៏ដោយ ។ ព្រះអង្គសង្គ្រោះបានបង្ហាញផ្លូវដល់យើង។ នៅក្នុងសួនច្បារគេតសេម៉ានី នៅលើឈើឆ្កាង ហើយនិងនៅក្នុងផ្នូរ ទ្រង់បានក្រោកឡើងដោយនាំមកនូវជីវិត និងសេចក្ដីសង្ឃឹមដល់យើងគ្រប់រូប។ ថ្ងៃនេះ ដូចដែលទ្រង់បានមានបន្ទូល កាលនៅលើផែនដី ទ្រង់ប្រាប់យើងថា «ចូរ មកតាមខ្ញុំ»។

ប្រធាន ថូម៉ាស អេស ម៉នសុន បានប្រឹក្សាថា៖ «ប្រសិនបើយើងនឹងដើរដោយងើបមុខឆ្ពោះទៅមុខ យើងត្រូវតែបរិច្ចាគចំពោះជីវិតយើង។ ប្រសិនបើយើងនឹងបំពេញនូវវាសនារបស់យើង ហើយត្រឡប់ទៅរស់នៅជាមួយព្រះវរបិតានៅស្ថានសួគ៌វិញ យើងត្រូវតែគោរពបញ្ញត្តិរបស់ទ្រង់ និងដាក់គន្លងជីវិតរបស់យើងតាមព្រះអង្គសង្គ្រោះ។ ដោយការធ្វើដូច្នោះ យើងនឹងមិនគ្រាន់តែសំរេចបាននូវគោលដៅសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ចប៉ុណ្ណោះទេ ប៉ុន្តែយើងនឹងធ្វើឲ្យពិភពលោកកាន់តែសម្បូរណ៍ហូរហៀរ និងប្រសើរជាងពេលយើងមិនបាន *រស់នៅ និងបំពេញតាមភារកិច្ចរបស់យើងទៅទៀត*» ។

នៅក្នុងព្រះគម្ពីរបរិសុទ្ធមានចែងនូវពាក្យពេចន៍ដ៏បំផុសគំនិតថា « ការណ៍ទាំងអស់បានសំដែងទុកហើយ ដូច្នេះ ចូរកោតខ្លាចដល់ព្រះ ហើយកាន់តាមបញ្ញត្តិទ្រង់ចុះ *ត្បិតប៉ុណ្ណោះឯងជាកិច្ចទាំងមូលដែលមនុស្សត្រូវធ្វើ*» ។

**តើអ្វីទៅដែលហៅថាកាតព្វកិច្ច?**

កាតព្វកិច្ចដែលខ្ញុំលើកឡើងនេះ គឺជាអ្វីដែលយើងត្រូវបានរំពឹងទុកថានឹងត្រូវធ្វើ និងក្លាយខ្លួនទៅជា។ វាជាសារៈសំខាន់ខាងសីលធម៌ដែលដាស់តឿនចេញមកអំពីបុគ្គល និងសហាគមនូវអ្វីដែលត្រឹមត្រូវ ពិត និងគួរឲ្យគោរព។ កាតព្វកិច្ចមិនចាំបាច់ត្រូវការសេចក្ដីល្អឥតខ្ចោះនោះទេ ប៉ុន្តែវាត្រូវការភាពអំណត់ព្យាយាមវិញ។ វាមិនមែនគ្រាន់តែជាអ្វីដែលស្របតាមច្បាប់ប៉ុណ្ណោះឡើយ ប៉ុន្តែ វាគឺជាអ្វីដែលមានគុណធម៌។ វាមិនត្រូវបានរក្សាទុកសម្រាប់តែអ្នកខ្លាំង ឬឋានៈខ្ពស់ឡើយ ប៉ុន្តែផ្ទុយទៅវិញ វាស្ថិតនៅលើមូលដ្ឋានគ្រឹះនៃការទទួលខុសត្រូវ ភាពទៀងត្រង់ និងភាពក្លាហានផ្ទាល់ខ្លួន។ ការធ្វើតាមកាតព្វកិច្ចរបស់មនុស្សម្នាក់ គឺជាការសម្ដែងចេញនូវសេចក្ដីជំនឿ ។

ប្រធាន មនសុន បានមានប្រសាសន៍អំពីពាក្យនេះថា «ខ្ញុំស្រលាញ់ និងរីករាយជាមួយនឹងពាក្យដ៏ឧត្ដុងឧត្ដម គឺជាពាក្យ *កាតព្វកិច្ច ។"* សម្រាប់សមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ គន្លងនៃ កាតព្វកិច្ចរបស់យើងគឺការគោរពសេចក្ដីសញ្ញារបស់យើងនៅក្នុងជីវិតប្រចាំថ្ងៃ។

## តើកាតព្វកិច្ចរបស់យើងត្រូវមានចំពោះនរណា និងអ្វីខ្លះ?

ទីមួយ គន្លងនៃកាតព្វកិច្ចរបស់យើងគឺចំពោះព្រះ ដែលជាព្រះវរបិតាដ៏អស់កល្ប។ ទ្រង់គឺជាអង្គបង្កើតផែនការសង្គ្រោះ ជាអង្គរៀបចំស្ថានសួគ៌ និងផែនដី ជាអង្គបង្កើត អ័ដាម និង អេវ៉ា។ ទ្រង់គឺជាប្រភពនៃសេចក្ដីពិត ជានិមិត្តរូបនៃសេចក្ដីស្រលាញ់ និងជាបុព្វហេតុធ្វើឲ្យមានការប្រោសលោះ ។

ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានមានប្រសាសន៍ថាៈ «អ្វីដែលយើងមានគឺបានមកពី [ព្រះ] ...។ នៅក្នុងរបស់ខ្លួនយើង យើងគ្រាន់តែជាដីដែលគ្មានជីវិតមួយដុំប៉ុណ្ណោះ។ ជីវិត បញ្ញា គតិបណ្ឌិត ការវិនិច្ឆ័យអំណាចនៃការទាញរកហេតុផលទាំងអស់នោះ សុទ្ធតែជាអំណោយរបស់ព្រះចំពោះកូនចៅមនុស្ស។ ទ្រង់ផ្ដល់ដល់យើងនូវកម្លាំងខាងរាងកាយ ក៏ដូចជា អំណាចខាងស្មារតីរបស់យើងផងដែរ។ មនុស្ស...គ្រប់រូបគួរតែមានអារម្មណ៍អំពីជម្រៅនៃដួងចិត្តរបស់ខ្លួនថា ពួកគេជំពាក់ ព្រះគុណដល់ព្រះដ៏មហិមាសម្រាប់រូបកាយរបស់ខ្លួន  និងលក្ខណៈសម្បត្តិដែលពួកគេមាន ដូចជាលក្ខណៈសម្បត្តិរបស់ព្រះ...។ យើងគួរគោរពព្រះឲ្យអស់ពីបញ្ញា កម្លាំង ការយល់ដឹង គតិបណ្ឌិតរបស់យើង ហើយនិងឲ្យអស់ពីអនុភាពដែលយើងមាន។ យើងគួរព្យាយាមធ្វើអំពើល្អក្នុងពិភពលោកនេះ។ *នេះគឺជា កាតព្វកិច្ចរបស់យើង ។*»

មនុស្សម្នាក់មិនអាចធ្វើកាតព្វកិច្ចចំពោះព្រះដែលជាព្រះវរបិតា ដោយមិនបានធ្វើដូចជាព្រះរាជបុត្រារបស់ព្រះ ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទបានឡើយ។ ទ្រង់គឺជាព្រះអង្គប្រោសលោះ និងជាស្ដេចរបស់យើង។ ទោះពួកទ្រង់មិនមែនជាអង្គតែមួយក៏ដោយ ក៏ទ្រង់មានគោលបំណងតែមួយដែរ។ ដើម្បីថ្វាយបង្គំព្រះមួយអង្គតម្រូវឲ្យមានការថ្វាយបង្គំសម្រាប់អង្គមួយទៀត ពីព្រោះព្រះវរបិតាបានបញ្ជាថា គឺតាមតែរយៈព្រះនាមនៃព្រះគ្រីស្ទប៉ុណ្ណោះដែលយើងអាចបំពេញនូវភារកិច្ចដែលទ្រង់ដាក់ឲ្យបានពេញលេញ។

ក្នុងនាមជាបុរសស្ត្រី និងជាកុមារាកុមារី ការបំពេញកាតព្វកិច្ចចំពោះព្រះ នឹងជួយពួកគេបានទទួលអារម្មណ៍នៃការលើកទឹកចិត្ត ដើម្បីបំពេញកាតព្វកិច្ចចំពោះអ្នកដទៃ ចំពោះក្រុមគ្រួសាររបស់គេ ចំពោះព្រះវិហារ និងជាតិរបស់ពួកគេ ចំពោះគ្រប់រឿងទាំងអស់ ដែលត្រូវការការថែរក្សារបស់ពួកគេ។ ពួកគេត្រូវចងភ្ជាប់ដោយភារកិច្ច ដើម្បីពង្រីកនូវទេពកោសល្យ របស់ពួកគេ និងដើម្បីធ្វើជាមនុស្សល្អ និងគោរពច្បាប់។ ពួកគេទៅជាមនុស្សដាក់ខ្លួន រាបសា និង ទទួលយកយ៉ាងងាយស្រួល។ ការចេះប្រមាណយកឈ្នះលើការហួសហេតុ ការស្ដាប់បង្គាប់ដឹកនាំការអំណត់តស៊ូរបស់ពួកគេ។ សេចក្ដីសុខសាន្តកើតឡើងចំពោះពួកគេ។ ពលរដ្ឋទៅជាស្មោះស្ម័គ្រ។ សហាគមន៍ទៅជាមានចិត្តមេត្តា ហើយអ្នកជិតខាងទៅជា មិត្តភ័ក្ដ។ ព្រះនៃស្ថានសួគ៌សព្វព្រះទ័យផែនដីមានភាពស្ងប់ស្ងាត់ ហើយពិភពលោកក្លាយជាកន្លែងដែលល្អជាងមុន ។

វាគឺជាវិធីដ៏ច្បាស់លាស់មួយដែលអ្នករាល់គ្នាអាចដឹង។ វាជាខ្សែជីវិតរបស់មនុស្សរាល់គ្នាសម្រាប់ការឆ្ពោះទៅកាន់ស្ថានសួគ៌។ សាវក ប៉ុលបានមានប្រសាសន៍ថា៖ «ព្រះនេត្រនៃព្រះអម្ចាស់តែងទតមកលើមនុស្សសុចរិត ឯព្រះកាណ៌ទ្រង់ក៏ផ្ទៀងស្ដាប់ ពាក្យ ទូលអង្វររបស់គេ» ។

ការអធិស្ឋានដែលរាបសា ស្មោះត្រង់ បំផុសគំនិត ផ្ដល់ដល់យើងគ្រប់រូបនូវការដឹកនាំ ដែលយើងត្រូវការចាំបាច់បំផុតមកពីព្រះ។ ព្រិកហាំ យ៉ង់ បានផ្ដល់ប្រឹក្សាថា «នៅពេលខ្លះ មនុស្សមានភាពច្របូកច្របល់ និងពោរពេញទៅដោយការខ្វល់ខ្វាយ និងបញ្ហា... ប៉ុន្តែការវិនិច្ឆ័យរបស់យើងបង្រៀនយើងថា វាជាកាតព្វកិច្ចរបស់យើង ដើម្បីអធិស្ឋាន»។

ព្រះយេស៊ូវបង្រៀនថា៖ «ប្រាកដមែន អ្នករាល់គ្នាត្រូវចាំយាម ហើយអធិស្ឋានជានិច្ច ខ្លាចក្រែងអ្នកធ្លាក់ទៅក្នុងសេចក្ដីល្បួង ត្បិតអារក្សសាតាំងមានបំណងចង់បានអ្នករាល់គ្នា ដើម្បីវាអាចរែងអ្នករាល់គ្នាដូចជាស្រូវអញ្ចឹង ។ដូច្នេះ អ្នករាល់គ្នាត្រូវតែអធិស្ឋានដល់ព្រះវរបិតា ដោយនូវនាមយើងជានិច្ច ហើយសូម្បីជាអ្វីដែលអ្នករាល់គ្នាសុំព្រះវរបិតា ដោយនូវនាមយើង ដែលត្រឹមត្រូវ និងដោយជឿថា អ្នកនឹងបានទទួលមើលចុះ នឹងបានប្រទានដល់អ្នក។ ចូរអធិស្ឋាននៅក្នុងក្រុមគ្រួសារអ្នក ដល់ព្រះវរបិតាដោយនូវនាមយើងជានិច្ច ដើម្បីឲ្យប្រពន្ធរបស់អ្នក និងកូនចៅរបស់ អ្នកបានពរ»។

ដើម្បីឲ្យការអធិស្ឋានមានប្រសិទ្ធភាព ពួកគេត្រូវតែស្ថិតនៅស្របគ្នាជាមួយនឹងផែនការនៃស្ថានសួគ៌។ ការអធិស្ឋានដោយជំនឿផ្ដល់ផ្លែផ្កា នៅពេលមានគន្លងស្របគ្នានេះ ហើយគន្លងស្របគ្នានេះមានបាននៅពេលអធិស្ឋានត្រូវបានបំផុសគំនិតដោយព្រះវិញ្ញាណបរិសុទ្ធ។ ព្រះវិញ្ញាណបង្ហាញនូវអ្វីដែលយើងគួរទូលសុំ។ បើគ្មានការដឹកនាំដ៏បំផុសគំនិតនេះ យើងនឹង «ទូលសុំ» ដើម្បីស្វែងរកតែតាមឆន្ទៈរបស់យើងប៉ុណ្ណោះ និងមិនតាម «ឆន្ទៈទ្រង់» ឡើយ។ វាជាការសំខាន់ដែលយើងត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ នៅពេលយើងអធិស្ឋាន ដូចដែលយើងទទួលបានការបំភ្លឺដោយព្រះវិញ្ញាណដូចគ្នានេះ នៅពេលយើងទទួលបានចម្លើយចំពោះការអធិស្ឋាន។ ការអធិស្ឋានបែបនេះនាំមកនូវពរជ័យនៃស្ថានសួគ៌ ពីព្រោះព្រះវរបិតារបស់យើង «ទ្រង់ជ្រាបនូវរបស់អ្វីដែល [យើង] ត្រូវការ មុនដែល [យើង] សុំ» ទៅទៀត ហើយ

ទ្រង់ឆ្លើយតបចំពោះការអធិស្ឋានដែលស្មោះត្រង់។ នៅទីបំផុត គឺទ្រង់ផ្ទាល់ដែលបាសន្យាថា «ចូរសុំនោះនឹងតែងឲ្យអ្នក ចូរគោះ នោះតែងនឹងបើកឲ្យអ្នក»។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា គន្លងនៃកាតព្វកិច្ចនេះត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់ដោយសេចក្តីជំនឿ និងការជឿដែលមិនអាចបែងចែកបានទៅលើព្រះ ដែលជាព្រះវរបិតាដ៏អស់កល្បរបស់យើង និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ និងអនុភាពនៃការអធិស្ឋាន។ គន្លងនេះត្រូវបានធ្វើដំណើរដោយកូនចៅរបស់ព្រះទាំងអស់ដែលស្រលាញ់ទ្រង់ ហើយនិងមានគោល បំណងគោរពតាមព្រះបញ្ញត្តិ។ ចំពោះមនុស្សវ័យក្មេង វានឹងនាំទៅរកការជោគជ័យផ្ទាល់ខ្លួន និងការរៀបចំខ្លួន ។ សម្រាប់មនុស្សពេញវ័យ វានឹងនាំទៅរកសេចក្តីជំនឿថ្មីឡើងវិញ និងដំណោះស្រាយ។ ចំពោះមនុស្សមានវ័យចំណាស់ វានឹងនាំទៅរកទស្សនៈវិស័យ និងការស៊ូទ្រាំនៅក្នុងសុចរិតភាពដល់ទីបញ្ចប់។ វាបំពាក់ឲ្យអ្នកធ្វើដំណើរដែលមានជំនឿ នូវកម្លាំងនៃព្រះអម្ចាស់ ការការពារអ្នកដំណើរនោះពីអំពើអាក្រក់នៅពេលនោះ ហើយផ្តល់ដល់ពួកគេនូវចំណេះដឹងថា «សេចក្តីទាំងអស់បានសំដែងទុកហើយ ដូច្នេះចូរកោតខ្លាចដល់ព្រះ ហើយកាន់តាមព្រះបញ្ញត្តិទ្រង់ចុះ ត្បិតប៉ុណ្ណោះឯងជាកិច្ចទាំងមូលដែលមនុស្សត្រូវធ្វើ» ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

កំណត់ចំណាំ

1. ម៉ូសេ 7:61; អក្សរទ្រេតជាការបន្ថែម

2. Joseph F. Smith, Gospel Doctrine, 5th ed. [ឆ្នាំ 1939] ទំព័រ 156។

3. ម៉ូសាយ 1:17

4. អាល់ម៉ា 7:22។

5. ហេលេមិន 15:5

6. See Corrie ten Boom, A Chilling Encounter, Latter-day Saint Companion---Motivational Stories, Inspired Poetry. [Original source could be from The Hiding Place or Tramp for the Lord (1974)]

7. លូកា 18:22។

8. Thomas S. Monson, in Conference Report, Dortmund Germany Area Conference, 1976, page? ការគូសបញ្ជាក់បានដាក់បន្ថែម។

9. សាស្ដ្រា 12:13; អក្សរទ្រេតជាការបន្ថែម ។

10. Thomas S. Monson «Duty Calls» Ensign ខែ ឧសភា ឆ្នាំ 1996 ទំព័រ 43។

11. សូមមើល គ. និង ស. 20:17--19។

12. សូមមើល គ. និង ស. 93:36។

13. សូមមើល យ៉ូហានទី1 4:8។

14. សូមមើល យ៉ូហាន 3:16; ហេលេមិន 5:10--11។

15. Joseph F. Smith នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1899 ទំព័រ 69, 70 ការគូសបញ្ជាក់បានដាក់បន្ថែម។

16. សូមមើល មរ៉ូណៃ 10:32--33 គ. និង ស. 59:5។

17. សូមមើល អាល់ម៉ា 7:23, 27។

18. ពេត្រុស ទី 1 3:12, 15។

19. Discourses of Brigham Young រៀបរៀងដោយ John A. Widtsoe [ឆ្នាំ 1954] ទំព័រ 45 ការគូសបញ្ជាក់បានដាក់បន្ថែម។

20. នីហ្វៃ ទី 3 18:18--21។

21. សូមមើល គ. និង ស. 50:29--30។

22. យ៉ាកុប 4:3។

23. យ៉ាកុប 4:3។

24. ម៉ាថាយ 6:8។

25. ម៉ាថាយ 7:7; សូមមើល Joseph Smith Translation ម៉ាថាយ 7:12—13 នៅក្នុង Bible appendix។

26. សាស្ត្រា 12:13 អក្សរទ្រេតបន្ថែម ។